# ព្រះរាជក្រឹត្យ

នស/រកត/០៨២៣/ ១៥៤៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានទ្រង់យល់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាអគ្គមគ្គុទេសក៍ដ៏ល្អឆ្នើម និងប៉ិនប្រសប់ ឈ្លាសវៃដ៏ល្អប្រសើរបំផុត ជាទីគោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់របស់ប្រជារាស្ត្រ បានដឹកនាំប្រជាជាតិកម្ពុជា តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ កសាងបាននូវសន្តិភាពជាតិ ស្ថិរភាពជាតិ ឯកភាពជាតិ ការអភិវឌ្ឍជាតិយ៉ាងច្បាស់លាស់លើគ្រប់វិស័យ ការពារលទ្ធិប្រជាធិបតេយ្យ និងមានកិច្ចសហប្រតិបត្តិការអន្តរជាតិល្អ ព្រមទាំងរក្សាបាននូវឯករាជ្យជាតិ និងបូរណភាពទឹកដី តាមទស្សនវិស័យ នៃ **សង្គមរាស្ត្រនិយម** ក្រោមព្រះរាជកិច្ចដឹកនាំដ៏ឈ្លាសវៃរបស់ **ព្រះករុណា ព្រះបរមរតនកោដ្ឋ** ។
- បានទ្រង់យល់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាអគ្គមគ្គុទេសក៍ដ៏ល្អប្រសើរ ជាទីគោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់របស់ប្រជារាស្ត្រ បានចូលរួមដឹកនាំកសាងប្រទេសជាតិ និងគោរពព្រះពុទ្ធសាសនា និងសាសនាផ្សេងៗទៀត ឱ្យមានការរីកចម្រើននៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងមានស្វាមីភក្តិចំពោះរាជបល្ល័ង្ក ការពារនិរន្តរភាព រាជានិយមនៃព្រះរាជាណាចក្រកម្ពុជា ។

## ត្រាស់បង្គាប់

**តែងតាំង :**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ជា**

**ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ**
**នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ នាយករដ្ឋមន្ត្រី**

ពរស.២៣០៥.២០០០

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២២ ខែសីហា ឆ្នាំ២០២៣*

# ព្រះរាជក្រឹត្យ

នស/រកត/០៨២៣/ ១៩៧៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានទ្រង់យល់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ជាអគ្គមគ្គទេសក៍ដ៏ល្អប្រសើរ ជាទីគោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់របស់ប្រជារាស្ត្រ បានដឹកនាំប្រជាជាតិកម្ពុជា តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានកសាងប្រព័ន្ធច្បាប់ សម្រាប់ប្រើប្រាស់ជាឧត្តមប្រយោជន៍ដល់សង្គមជាតិ ទទួលបាននូវសន្តិភាពជាតិ ស្ថិរភាពជាតិ ឯកភាពជាតិ ការអភិវឌ្ឍជាតិ លើគ្រប់វិស័យ ការពារលទ្ធិប្រជាធិបតេយ្យ និងមានកិច្ចសហប្រតិបត្តិការអន្តរជាតិល្អ ព្រមទាំងរក្សាបាននូវឯករាជ្យជាតិ និងបូរណភាពទឹកដី ព្រមទាំងបានចូលរួមដឹកនាំកសាង និងគោរពព្រះពុទ្ធសាសនា ព្រមទាំងសាសនាផ្សេងៗទៀត ឱ្យមានការរីកចម្រើន នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។
- បានទ្រង់យល់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ជាអគ្គមគ្គទេសក៍ដ៏ល្អប្រសើរ ជាទីគោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់របស់ប្រជារាស្ត្រ មានស្វាមីភក្តិចំពោះរាជបល្ល័ង្ក ការពារនិរន្តរភាពរាជានិយម នៃព្រះរាជាណាចក្រកម្ពុជា ។

**ត្រាស់បង្គាប់**

**តែងតាំង :**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

**ជា**

**ប្រធានកិត្តិយសនៃក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ**
**នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ នាយករដ្ឋមន្ត្រី**

៣-ស. ២៣០៨. ១៩៩៩

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០២៣*

# ព្រះរាជក្រឹត្យ

នស/រកត/០៨២៣/ ១៩៨៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។
- បានទ្រង់យល់ សម្តេចក្រឡាហោម **ស ខេង** ជាអ្នកដឹកនាំដ៏ឆ្នើម ជាទីគោរពស្រឡាញ់របស់ប្រជារាស្ត្រ បានចូលរួមជួយដឹកនាំប្រជាជាតិកម្ពុជា តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានចូលរួមកសាងប្រព័ន្ធច្បាប់ និងអនុវត្តច្បាប់សម្រាប់ប្រើប្រាស់ជាឧត្តមប្រយោជន៍ដល់សង្គមជាតិ ទទួលបាននូវសន្តិភាព ស្ថិរភាព ឯកភាពជាតិ ការអភិវឌ្ឍជាតិលើគ្រប់វិស័យ ការពារលទ្ធិប្រជាធិបតេយ្យ ការពារជាតិ មានស្ថិរភាព សន្តិសុខសង្គមបានល្អប្រសើរ និងមានកិច្ចសហប្រតិបត្តិការ អន្តរជាតិ ព្រមទាំងរក្សាបាននូវឯករាជ្យជាតិ និងបូរណភាពទឹកដី ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ។
- បានទ្រង់យល់ សម្តេចក្រឡាហោម **ស ខេង** ជាអ្នកដឹកនាំដ៏ឆ្នើម ជាទីគោរពស្រឡាញ់របស់ប្រជារាស្ត្រ មានស្មារតីភក្តីចំពោះរាជបល្ល័ង្ក ការពារ និងគោរពព្រះពុទ្ធសាសនា ចូលរួមការពារនិរន្តរភាពរាជានិយមនៃព្រះរាជាណាចក្រកម្ពុជា។

## ត្រាស់បង្គាប់

**តែងតាំង :**

**សម្តេចក្រឡាហោម ស ខេង**

**ជា**

**ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ**
**នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ឧបនាយករដ្ឋមន្ត្រី**

៣៩ល-២៣០៨.២០០១

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែសីហា ឆ្នាំ២០២៣*

# ព្រះរាជក្រឹត្យ

នស/រកត/០៨២៣/ ១៩៥៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។
- បានទ្រង់យល់ សម្តេចពិជ័យសេនា **ទៀ បាញ់** ជាអ្នកដឹកនាំដ៏ឆ្នើម ជាទីគោរពស្រឡាញ់របស់ប្រជារាស្ត្រ បានចូលរួមជួយដឹកនាំប្រជាជាតិកម្ពុជា តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានចូលរួមកសាងប្រព័ន្ធច្បាប់សម្រាប់ប្រើប្រាស់ជាឧត្តមប្រយោជន៍ដល់សង្គមជាតិ ទទួលបាននូវសន្តិភាព ស្ថិរភាព ឯកភាពជាតិ ការអភិវឌ្ឍជាតិលើគ្រប់វិស័យ ការពារលទ្ធិប្រជាធិបតេយ្យ ការពារជាតិ មានស្ថិរភាព សន្តិសុខសង្គមបានល្អប្រសើរ និងមានកិច្ចសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងរក្សាបាននូវឯករាជ្យជាតិ និងបូរណភាពទឹកដី ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ។
- បានទ្រង់យល់ សម្តេចពិជ័យសេនា **ទៀ បាញ់** ជាអ្នកដឹកនាំដ៏ឆ្នើម ជាទីគោរពស្រឡាញ់របស់ប្រជារាស្ត្រ មានស្វាមីភក្តិចំពោះរាជបល្ល័ង្ក ការពារ និងគោរពព្រះពុទ្ធសាសនា ចូលរួមការពារនិរន្តរភាពរាជានិយមនៃព្រះរាជាណាចក្រកម្ពុជា។

**ត្រាស់បង្គាប់**

**តែងតាំង :**

**សម្តេចពិជ័យសេនា ទៀ បាញ់**

**ជា**

**ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ**
**នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ឧបនាយករដ្ឋមន្ត្រី**

ត្រស. ២៣០៥.២០០៤

នសីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែសីហា ឆ្នាំ២០២៣*

## ព្រះរាជក្រឹត្យ

នស/រកត/០៨២៣/ ១៩៨៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។
- បានទ្រង់យល់ សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ជាអ្នកដឹកនាំដ៏ឆ្នើម ជាទីគោរពស្រឡាញ់របស់ប្រជារាស្ត្រ បានចូលរួមជួយដឹកនាំប្រជាជាតិកម្ពុជា តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានចូលរួមកសាងប្រព័ន្ធច្បាប់សម្រាប់ប្រើប្រាស់ជាឧត្តមប្រយោជន៍ដល់សង្គមជាតិ ទទួលបាននូវសន្តិភាព ស្ថិរភាព ឯកភាពជាតិ ការអភិវឌ្ឍជាតិលើគ្រប់វិស័យ ការពារលទ្ធិប្រជាធិបតេយ្យ ការពារជាតិ មានសន្តិសុខសង្គមបានល្អប្រសើរ និងមានកិច្ចសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងរក្សាបាននូវឯករាជ្យជាតិ និងបូរណភាពទឹកដី ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ និងឈ្លាសវៃរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ។
- បានទ្រង់យល់ សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ជាអ្នកដឹកនាំដ៏ឆ្នើម ជាទីគោរពស្រឡាញ់របស់ប្រជារាស្ត្រ មានស្វាមីភក្តិចំពោះរាជបល្ល័ង្ក ការពារ និងគោរពព្រះពុទ្ធសាសនា ចូលរួម

### ត្រាស់បង្គាប់

**តែងតាំង :**

**សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន**

**ជា**

**ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ**

**នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ឧបនាយករដ្ឋមន្ត្រី**

៣រស-២៣០៨.២០០៣

នរោត្តមសីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២២ ខែសីហា ឆ្នាំ២០២៣*